ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រៃវែង**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ៥៩០

ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០២០

សាលក្រមលេខ: ២៧៥/៦៨ (ក)

ចុះថ្ងៃចន្ទ ០៥រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ ត្រូវនឹងថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូង ខេត្តព្រៃវែង

បានបើកសវនាការជាសាធារណៈ និង ប្រកាសជាសាធារណៈ នៅសាលាដំបូងខេត្តព្រៃវែង នៅថ្ងៃទី១៨ ខែកក្កដាឆ្នាំ២០២២ ដោយមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

**-ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តព្រៃវែង**

**តំណាងអយ្យការ**

**-លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រៃវែង**

**ក្រឡាបញ្ជីសវនាការ**

**-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រៃវែង**

**មេធាវីការពារអោយជនជាប់ចោទ**

**លោក [redacted]**

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៩ ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ:

១.ឈ្មោះ [redacted] ឡុច ភេទប្រុស អាយុ ៥៨ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនា ព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ[redacted] ព្រៃវែង និងទីលំនៅបច្ចុប្បន្ន [redacted] ខេត្តព្រៃវែង មុខរបរៈកសិករ កម្រិតវប្បធម៌ៈថ្នាក់ទី

០១ ប្រពន្ធឈ្មោះ [redacted] ម៉ៅ មានកូនចំនួន ០៥ នាក់ ឪពុកឈ្មោះ [redacted] គរ (ស) ម្ដាយឈ្មោះ [redacted] យិន (ស) ជានីតិជន ទោសពីមុនះមាន។ (ក្នុងឃុំ)

ជាប់ចោទពីបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិទង់នាគ ឃុំស្ដៅកោង ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា២១៨ ចំណុចទី២ នៃច្បាប់ក្រមព្រហ្មទណ្ឌ ។

**១.អង្គហេតុនៃបណ្ដឹងចោទប្រកាន់**

កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៩ និង ០០នាទី នៅចំណុចភូមិទង់នាគ ឃុំស្ដៅកោង ស្រុកបាភ្នំ ខេត្តព្រៃវែង មានឈ្មោះ [redacted] ឡុច ភេទប្រុស អាយុ ៥០ ឆ្នាំ (មានសាវតាជាតិដូចខាងលើ) និងប្រពន្ធឈ្មោះប្រកែកគ្នា នៅក្នុងពេលនោះដែរមានឈ្មោះ [redacted] ស៊ីនឿន ភេទប្រុស អាយុ ២០ ឆ្នាំ រស់នៅភូមិឃុំជាមួយគ្នាដែលត្រូវជាប្អូនថ្លៃ បានចូលទៅឃាត់កុំឲ្យឈ្លោះគ្នា ស្រាប់តែឈ្មោះ [redacted] ឡុច បានយកកំបិតផ្គាក់កាប់ទៅលើជនរងគ្រោះឈ្មោះ ដួង ស៊ីនឿន ត្រូវចំក្បាល និងខ្លួនចំនួន ០៦ កន្លែង បណ្ដាលឲ្យរងរបួសធ្ងន់ហូរឈាម និងសន្លប់នៅកន្លែងកើតហេតុតែម្ដង។ ក្រោយពេលប្រព្រឹត្តរួចឈ្មោះ [redacted] ឡុច រត់គេចខ្លួនបាត់ទៅ ចំណែកឈ្មោះ [redacted] ស៊ីនឿន ត្រូវក្រុមគ្រួសារយកទៅព្យាបាលនៅមន្ទីរពេទ្យ ។

-បានឃើញ ដីកាដំណោះស្រាយលេខ ១០៦២ ជស.ព្រទ/២២ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រៃវែង ។

-បានឃើញ កំណត់ហេតុជំនុំជម្រះរបស់សាលាដំបូងខេត្តព្រៃវែង ចុះថ្ងៃទី១៨ខែកក្កដា ឆ្នាំ ២០១៩។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារអោយជនជាប់ចោទ

-ក្រោយពីបានស្ដាប់សម្ដីចុងក្រោយរបស់ជនជាប់ចោទ

**២.ផ្នែកសំអាងហេតុ**

**ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

**សាលាដំបូងខេត្តព្រៃវែង យល់ឃើញថា ៖**



Scanned with CamScanner

២.១.ជនជាប់ចោទឈ្មោះ [redacted] ឡុច ភេទប្រុស អាយុ៥០ឆ្នាំ (មានសាវតាជាតិដូចខាងលើ) ត្រូវបានចៅក្រមស៊ើបសួរប្តឹងចោទពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិទង់នាគ ឃុំស្ដៅកោង ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា២១៨ ចំណុចទី២ នៃច្បាប់ក្រមព្រហ្មទណ្ឌ តាមដីកាដំណោះស្រាយលេខ ១០៦៤ ជស.ព្រ ទ/២២ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រៃវែង ។

## ក.អំពីបញ្ញត្តិច្បាប់:

២.២.អំពើល្មើសដែលរងការចោទប្រកាន់បានប្រព្រឹត្តឡើងថ្ងៃទី១០ខែតុលា ឆ្នាំ២០២០ ដូចនេះអំពើនេះត្រូវស្ថិតក្នុងវិសាលភាពនៃច្បាប់ក្រមព្រហ្មទណ្ឌ ។

## ខ.អំពីពិរុទ្ធភាព:

២.៣.កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៩ និង ០០នាទី នៅចំណុចភូមិទង់នាគ ឃុំស្ដៅកោង ស្រុកបាភ្នំ ខេត្តព្រៃវែង មានឈ្មោះ [redacted] ឡុច ភេទប្រុស អាយុ ៥០ ឆ្នាំ (មានសាវតាជាតិដូចខាងលើ) និងប្រពន្ធបានឈ្លោះប្រកែកគ្នា នៅក្នុងពេលនោះដែរមានឈ្មោះ [redacted] ស៊ីនឿន ភេទប្រុស អាយុ ២០ ឆ្នាំ រស់នៅភូមិឃុំជាមួយគ្នាដែលត្រូវជាប្អូនថ្លៃ បានចូលទៅឃាត់កុំឲ្យឈ្លោះគ្នា ស្រាប់តែឈ្មោះ [redacted] ឡុច បានយកកំបិតផ្គាក់កាប់ទៅលើជនរងគ្រោះឈ្មោះ [redacted] ស៊ីនឿន ត្រូវចំក្បាល និងខ្លួនចំនួន ០៦ កន្លែងបណ្តាលឲ្យរងរបួសធ្ងន់ហូរឈាមនិងសន្លប់នៅកន្លែងកើតហេតុតែម្តង។ ក្រោយពេលប្រព្រឹត្តរួចឈ្មោះ [redacted] ឡុច រត់គេចខ្លួនបាត់ទៅ ចំណែកឈ្មោះ [redacted] ស៊ីនឿន ត្រូវក្រុមគ្រួសារយកទៅព្យាបាលនៅមន្ទីរពេទ្យ ។

២.៤.នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ឡុច បានសារភាពថា នៅថ្ងៃខែមិនចាំឆ្នាំ ២០២០ នៅវេលាម៉ោង ០៥ ល្ងាច ប្រពន្ធរបស់ខ្លួនមិននៅផ្ទះក៏មិនបានបិទពោងលក់ដូរទេ ព្រោះគាត់បានទៅបុណ្យកឋិននៅក្នុងវត្ត ពេលដែលខ្លួនមកដល់ផ្ទះ ស្រាប់តែឃើញពោងលក់នៅមុខផ្ទះបើកទ្វារចំហរហើយខ្លួនក៏ស្រែកជេរទៅលើប្រពន្ធថាមីចោរឡាបល់យកទៅណាបានមិនបិទពោងលក់ចឹងក្រោយមកក៏ស្រាប់តែប្អូនថ្លៃឈ្មោះ [redacted]

ស៊ីនឿន បានស្រែកជេរមកលើខ្លួនថា អាចុយម៉ាយ ហើយវាក៏ជាក់របងផ្ទះ ស្ទុះចូលមកវាយខ្លួន ដោយដៃវាមានកាន់ឈើជ្រុងទុកទល់របងផ្ទះវាយមកលើខ្លួន តែខ្លួនគេចផុតខ្លួនក៏បានច្រានវាចេញ បណ្ដាលឲ្យវាដួលផ្កាប់មុខ ជុងទៅនិងរបង។ ពេលដែលវាដួលនោះខ្លួនបានឃើញឈាមហូរចេញពីមុខរបស់វាហើយខ្លួនក៏លើកវាអង្គុយផ្អែកទៅជញ្ជាំង រួចខ្លួនរត់ទៅហៅប្រពន្ធនៅក្នុងវត្តឲ្យមកផ្ទះ រួចក៏បានប្រាប់រឿងរ៉ាវទាំងអស់ទៅប្រពន្ធ ។

២.៧.តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីនឿន បានឆ្លើយថា កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៩ និង ៣០ នាទី ខ្លួនបានដើរមកពីវត្តគោកឃ្លោកមកផ្ទះវិញ ពេលខ្លួនដើរតាមផ្លូវក៏ឮឈ្មោះ [redacted] ឡុច ជៀលប្រពន្ធឈ្មោះ [redacted] ម៉ៅ ត្រូវជាបងបង្កើតរបស់ខ្លួន ពេលនោះខ្លួនដើរទៅឃាត់ខ្លួនកុំឲ្យឈ្លោះជេរជៀលគ្នាខ្មាសអ្នកជិតខាង រួចស្រាប់តែឈ្មោះ [redacted] ឡុច ទាញកាំបិតផ្គាក់កាប់មកលើខ្លួន បណ្ដាលឲ្យខ្លួនរបួសចំនួន ០៦ កាំបិត ធ្វើឲ្យបាត់បង់ស្មារតីដួលសន្លប់នៅកន្លែងកើតហេតុតែម្ដង ។

២.៨.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សំអន បានឆ្លើយថា កាលពីថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០២០ វេលាម៉ោង ១៩ និង ៣០ នាទី ខ្លួនជិះម៉ូតូតាមផ្លូវ ក៏ឃើញឈ្មោះ [redacted] ឡុច និងឈ្មោះ [redacted] ស៊ីនឿន កំពុងឈ្លោះប្រកែកគ្នា ខ្លួនក៏ឈប់ម៉ូតូហើយទៅឃាត់អ្នកទាំងពីរកុំឲ្យឈ្លោះប្រកែកគ្នា ខ្លួនបានឲ្យឈ្មោះ [redacted] ស៊ីនឿន ត្រលប់ទៅផ្ទះវិញតែឈ្មោះ [redacted] ស៊ីនឿន មិនព្រមទៅ ពេលនោះខ្លួនបានឃើញឈ្មោះ [redacted] ឡុច បានកាន់កាំបិតផ្គាប់កាប់ទៅលើឈ្មោះ [redacted] ស៊ីនឿន រួបខ្លួនភ័យក៏រត់ទៅប្រាប់ឈ្មោះ [redacted] ទូច ឲ្យប្រាប់ឈ្មោះ [redacted] ទូច ឲ្យប្រាប់សមត្ថកិច្ចពីរឿងនេះ ពេលខ្លួនត្រលប់មកយកម៉ូតូវិញ អត់ឃើញឈ្មោះ [redacted] ឡុច ទេ ឃើញតែឈ្មោះ [redacted] ស៊ីនឿន រងរបួសដេកសន្លប់នៅខាងជើងរោងលក់របស់ឈ្មោះ [redacted] ឡុច ពេលនោះខ្លួនបានជិះម៉ូតូទៅប្រាប់ឈ្មោះ [redacted] សុជា ថាឈ្មោះ [redacted] ឡុច កាប់ប្ដីថ្លៃងឈ្មោះ [redacted] ស៊ីនឿន មិនដឹងស្លាប់ឬរស់ទេ សន្លប់នៅក្បែររោងលក់ឈ្មោះ [redacted] ឡុច ។

២.៩.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ទូច បានឆ្លើយថា កាលពីថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០២០ វេលាម៉ោង ១៩ និង ០០ នាទី ខ្លួនកំពុងលក់ដូរនៅផ្ទះ ស្រាប់តែឃើញឈ្មោះ [redacted] សំអន រត់មកប្រាប់ខ្លួនឲ្យគេទៅសមត្ថកិច្ចផង ឈ្មោះ [redacted] ឡុច កាប់ទៅលើឈ្មោះ [redacted] ស៊ីនឿន មិនដឹងស្លាប់ឬរស់ទេ រួចខ្លួនបានគេទៅសមត្ថកិច្ចតែមិនបានទៅមកឈ្មោះ [redacted] ស៊ីនឿន ទេ ព្រោះខ្លួនរវល់លក់ដូរឥវ៉ាន់ ។

២.៩.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ម៉ៅ បានឆ្លើយថា កាលពីថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០២០ វេលាម៉ោង ១៩ និង ០០ នាទី ប្តីរបស់ខ្លួនឈ្មោះ [redacted] ឡុច បានឈ្លោះនិងជេរជៀលរូបខ្លួន រួចរូបខ្លួនបានឃើញឈ្មោះ [redacted] ស៊ីនឿន ត្រូវជាប្អូនបង្កើតរបស់ខ្លួនចូលទៅដល់ហើយនិយាយថា ឈ្លោះជេរជៀលគ្នាមិនខ្មាសអ្នកជិតខាងទេអី ពេលនោះប្តីខ្លួនបានឈ្លោះប្រកែកជាមួយឈ្មោះ [redacted] ស៊ីនឿន ម្តង ខ្លួនបានពរចៅដើរទៅវត្តគោកឃ្លោកទៅ។ លុះដល់ម៉ោង ១៩ និង ០០ នាទី បានឮគេនិយាយតៗគ្នាថា ប្តីខ្លួនឈ្មោះ [redacted] ឡុច កាប់ទៅលើឈ្មោះ [redacted] ស៊ីនឿន បណ្តាលឲ្យរងរបួសពេលនោះខ្លួនបានឲ្យឈ្មោះ [redacted] ចន្ធូ ជូនទៅផ្ទះពេទ្យឯកជនឈ្មោះ ភាក់ នៅភូមិត្រពាំងស្វាយ ឃុំស្តៅកោង ស្រុកបាភ្នំ ពេលទៅដល់ខ្លួនបានឃើញឈ្មោះ [redacted] ស៊ីនឿន មានរបួសមែន ពេលខ្លួនត្រលប់មកផ្ទះវិញ ពុំឃើញប្តីខ្លួននៅផ្ទះទេ គឺរត់គេចខ្លួនបាត់ ។

២.១០.សំអាងតាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ចន្ធូ បានឆ្លើយថា កាលពីថ្ងៃទី ១០ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៨ និង ០០ នាទី ខ្លួននៅបុណ្យកឋិនវត្តគោកឃ្លោក លុះដល់ម៉ោង ១៩ និង ៣០ នាទី ខ្លួននៅវត្តដដែល ស្រាប់តែឈ្មោះ [redacted] ម៉ៅ ឲ្យខ្លួនជិះម៉ូតូជូនទៅផ្ទះពេទ្យឯកជនឈ្មោះ ភាក់ នៅភូមិត្រពាំងស្វាយ ឃុំស្តៅកោង ស្រុកបាភ្នំ ពេលទៅដល់ខ្លួនបានឃើញឈ្មោះ [redacted] ស៊ីនឿន មានរបួសមែន ខ្លួនលែងហ៊ានមើលក៏ជិះម៉ូតូត្រលប់មកវត្តគោកឃ្លោកវិញ ។

២.១១.សំអាងតាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សុជា បានឆ្លើយថា កាលពីថ្ងៃទី ១០ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៨ និង ០០ នាទី ខ្លួន និងប្តីបានមកធ្វើបុណ្យកឋិននៅវត្តគោកឃ្លោក លុះដល់ម៉ោង ១៨ និង ៤០ នាទី ខ្លួនមកផ្ទះមុនប្តី លុះដល់ម៉ោង ១៩ និង ០០ នាទី ខ្លួនបានឌុបម៉ូតូរបស់ឈ្មោះ [redacted] ចិន្តា ទៅតាមប្តីខ្លួន ពេលជិះបានប្រហែល

៤០០ម៉ែត្រ ក៏ជួបឈ្មោះ [redacted] សំអន ពេលនោះឈ្មោះ [redacted] សំអន បាននិយាយប្រាប់ថា ប្ដីខ្លួនឈ្មោះ [redacted] ស៊ីនឿន ពុំដឹងស្លាប់រស់នៅទេ ព្រោះឈ្មោះ [redacted] ឡុច កាប់ ហើយឥឡូវដេកសន្លប់នៅខាងជើងពេងលក់របស់ឈ្មោះ [redacted] ឡុច ពេលនោះខ្លួនបានជិះម៉ូតូទៅមើល ឃើញប្ដីដួលសន្លប់ ពេលខ្លួនលើកប្ដីឡើង ក៏ឃើញប្ដីមានរបួស ពេលនោះខ្លួនស្រែកហៅអ្នកជិតខាងជួយយកប្ដីព្យាបាលនៅពេទ្យ ។

២.១២.សកម្មភាពទាក់ទងនិង ហិង្សាដោយចេតនា ត្រូវបានហាមឃាត់ដោយច្បាប់របស់កម្ពុជាដូច្នេះការដែលជនជាប់ចោទ បានដឹងរួចហើយថាសកម្មភាពដែលខ្លួនបានធ្វើគឺជាអំពើខុសច្បាប់ ប៉ុន្តែពួកខ្លួននៅតែបន្តប្រព្រឹត្តនោះគឺពិតជាស្ដែងអោយចេញ ឃើញថា ចេតនាទុច្ចរិតពិតប្រាកដ របស់ជនជាប់ចោទក្នុងការប្រព្រឹត្តអំពើល្មើស ដែលបានចោទប្រកាន់។

២.១៣.យោងតាមសំអាងហេតុដូចបានចង្អុលបង្ហាញខាងលើស្ដែងឲ្យឃើញថា ជនជាប់ចោទ ពិតជាបានប្រព្រឹត្តអំពើ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា២១៨ ចំណុចទី២ នៃច្បាប់ក្រមព្រហ្មទណ្ឌ ។

២.១៤.ហេតុដូច្នេះ ពិតជាបង្ហាញឲ្យឃើញអំពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ឡុច ភេទប្រុស អាយុ៥០ឆ្នាំ (មានសារពើជាតិដូចខាងលើ) ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិទងនាគ ឃុំស្ដៅកោង ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា២១៨ ចំណុចទី២ នៃច្បាប់ក្រមព្រហ្មទណ្ឌ ។

## ក.អំពីឧណ្ឌកម្ម

២.១៥. កំរិតនៃទណ្ឌដែលមានកំណត់ក្នុងមាត្រា ២១៨ ចំណុចទី២ នៃច្បាប់ក្រមព្រហ្មទណ្ឌ មានកំរិតចាប់ពី ០២ឆ្នាំ រហូតដល់ ០៥ឆ្នាំ និងពិន័យជាប្រាក់ចំនួនចាប់ពី ២,០០០,០០០៛ (ពីរលានរៀល) ទៅ ១០,០០០,០០០៛ (ដប់លានរៀល) ដូច្នេះតុលាការពិចារណាពីការប្រកាសទោសក្នុងកំរិតដែលមានកំណត់នេះ ដោយផ្អែកលើច

រីក លក្ខណៈនៃអំពើដែលរងការចោទប្រកាន់ រួមជាមួយនិងកាលៈ ទេសៈបទល្មើស និងបុគ្គលិកលក្ខណៈនៃជនជាប់ចោទផងដែរ។

២.១៦.តាមការលើកឡើងរបស់ជនជាប់ចោទបង្ហាញអោយឃើញថា ជនជាប់ចោទនេះ មានជីវភាពក្រីក្រនិងជាអនក្ខរជនដូច្នេះពិតជាមិនមានការយល់ដឹងបានជ្រៅជ្រះ បានប្រាកដមែន។

២-១៧.ក្នុងចំណោមវត្ថុតាងដែលបានរឹបអូសឃើញថា មានវត្ថុតាងមួយចំនួនមានជាប់ពាក់ព័ន្ធទៅនឹងបទល្មើស រីឯ ចំនួនទៀតមិនមានបន្ទាល់បញ្ជាក់ថា មានជាប់ពាក់ព័ន្ធ ឬជាបច្ច័យដែលកើតចេញពីសកម្មភាពបទល្មើសនោះទេដូចនេះតុលាការពិចារណាដូចខាងក្រោមៈ

-កាំបិតផ្គាក់ ចំនួន ០១ គប្បីរឹបអូសនិងបំផ្លាញចោល ។

## ៣.ផ្នែកសេចក្ដីសម្រេច ៖
## ហេតុដូច្នេះសាលាដំបូងខេត្តព្រៃវែង
## វិនិច្ឆ័យសេចក្ដី

**៣.១.អំពីទណ្ឌកម្មៈ**

**ក.**ផ្ដន្ទាទោសលើៈ

.ឈ្មោះ[redacted] ឡុច ភេទប្រុស អាយុ៥០ឆ្នាំ (មានសាវតាជាតិដូចខាងលើ) និងដាក់ពន្ធនាគារកំណត់រយៈពេល ០២ ឆ្នាំ តែទោសក្នុងគុក កំណត់រយៈពេល ១២ ខែ ទោសដែលនៅសល់ព្យួរ និងត្រូវនិងពិន័យជាប្រាក់ចំនួន ៤,០០០,០០០៛(បួនលានរៀល) ។

ពីបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិទងនាគ ឃុំស្ដៅកោង ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា២១៨ ចំណុចទី២ នៃច្បាប់ក្រមព្រហ្មទណ្ឌ ។

**ខ. អំពីវត្ថុតាង**

វត្ថុតាងរួមមានៈ

-កាំបិតផ្គាក់ ចំនួន ០១ ត្រូវរឹបអូសនិងបំផ្លាញចោល ។

៣.២. សាលក្រមនេះជំនុំជម្រះនៅថ្ងៃព្រហស្បតិ៍ ០១រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃចន្ទ ០៥រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២ ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី និងចំពោះមុខជនជាប់ចោទ ។

សម្រេចបើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជី**

[redacted]

**ចៅក្រមជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ព្រៃវែង., ថ្ងៃទី.......ខែ.......ឆ្នាំ ២០...

ក្រឡាបញ្ជី

[redacted]